**សេចក្តីថ្លែងការណ៍ដោយគណៈប្រតិភូនៃសាធារណរដ្ឋទួរគី**
**ក្នុងកិច្ចប្រជុំលើកទី ១១ នៃរដ្ឋភាគីអនុសញ្ញា**
**ស្តីពីការហាមប្រាមការប្រើប្រាស់គ្រាប់មីន**
**[មាត្រា ៤]**
**(រាជធានីភ្នំពេញ ថ្ងៃទី ២៨ វិច្ឆិកា - ២ ធ្នូ ឆ្នាំ ២០១១**

លោកប្រធានជាទីគោរព
អនុលោមភាពពេញលេញជាមួយមាត្រា ៤ ពិតជាសសរស្តម្ភដ៏សំខាន់មួយនៃអនុសញ្ញាអូតាវ៉ា។

ខ្ញុំសូមធ្វើបច្ចុប្បន្នភាពស្តីពីការបំផ្លាញគ្រាប់មីនក្នុងឃ្លាំងនៅប្រទេសទួរគី។

ជាការពិតណាស់ យើងបានរាយការណ៍រួចហើយកាលពីឆ្នាំមុននៅក្នុងកិច្ចប្រជុំលើកទី១០ នៃរដ្ឋភាគី នៅហ្សឺណែវ ថា គិតមកដល់ពាក់កណ្តាលខែតុលា ឆ្នាំ២០១០ លើកលែងតែ "គ្រាប់មីនសម្លាប់ភូមិសាស្ត្រ" (ADAM) ចំនួន ២២.៧១៦ គ្រាប់ចេញ គ្រាប់មីនក្នុងឃ្លាំងទាំងអស់ត្រូវបានបំផ្លាញទាំងស្រុងនៅក្នុងកន្លែងបំផ្លាញយុទ្ធភ័ណ្ឌទួរគី ហើយកិច្ចសន្យាមួយត្រូវបានចុះហត្ថលេខាជាមួយទីភ្នាក់ងារថែទាំនិងផ្គត់ផ្គង់នៃអង្គការណាតូ (NATO) សម្រាប់ការបំផ្លាញគ្រាប់មីននៅសេសសល់ជាង ២២.០០០ គ្រាប់ បូករួមនឹងគ្រាប់មីន ដែលទាមទារឲ្យមានការចាត់ចែងពិសេស។ ខ្ញុំក៏បានជូនដំណឹងដល់រដ្ឋភាគីផងដែរថាគ្រាប់មីននៅសេសសល់ទាំងនេះត្រូវបានធ្វើឲ្យលែងដំណើរការបាន និងថាគ្រាប់មីនទាំងនេះកំពុងរង់ចាំការដឹកជញ្ជូនទៅប្រទេសទីបីដែលមានបរិក្ខារសមស្រប។

ស្របតាមអភិក្រមប្រកបដោយតម្លាភាពនិងស្មោះត្រង់របស់យើង យើងបានបន្តធ្វើបច្ចុប្បន្នភាពជាប្រចាំនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងខែមិថុនា ឆ្នាំ២០១១។ យើងបានជូនព័ត៌មានជាថ្មីម្តងទៀតដល់រដ្ឋភាគីនូវចំណុចខាងក្រោមៈ

១) នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ កិច្ចសន្យាមួយត្រូវបានចុះហត្ថលេខារវាងទីភ្នាក់ងារថែទាំនិងផ្គត់ផ្គង់នៃអង្គការ NATO (NAMSA) តាងនាមឲ្យរដ្ឋាភិបាលទួរគី និងក្រុមហ៊ុនមួយនៅប្រទេសអាល្លឺម៉ង់ (SpreewerkLübben GmbH) ដើម្បីការបំផ្លាញគ្រាប់មីនទាំងនេះដែលមានសារធាតុអ៊ុយរ៉ានីញ៉ូមខ្សោយ។

២) គ្រាប់មីនប្រភេទ ADAM សរុបចំនួន ៦៣១ (គ្រាប់មីននីមួយៗមានផ្ទុកគ្រាប់ចង្កោមចំនួន ៣៦ ដែលធ្វើឲ្យបរិមាណសរុបមានកើនដល់ ២២.៧១៦ គ្រាប់) បានចាកចេញពីដែនដីទួរគី និង ត្រូវបានដឹកកប៉ាល់ទៅកាន់ប្រទេសអាល្លឺម៉ង់ក្នុងខែ កុម្ភៈ ឆ្នាំ២០១១ ជាទីកន្លែងដែលសកម្មភាពបំផ្លាញបានចាប់ផ្តើមក្នុងខែ មីនា។

នៅពេលនេះ ខ្ញុំអាចប្រកាស តាមការបញ្ជាក់អះអាងដោយផ្ទាល់ពីរោងចក្រនៅប្រទេសអាល្លឺម៉ង់ថាការបំផ្លាញគ្រាប់មីនទាំងនេះ ត្រូវបានបញ្ចប់ទាំងស្រុងនៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១។

លោកប្រធានជាទីគោរព

តាំងពីមុនមកម្ល៉េះ ទួរគីបានបញ្ចប់រួចហើយនូវការបំផ្លាញគ្រាប់មីនជិត ៣ លានគ្រាប់ នៅមណ្ឌលបំផ្លាញគ្រាប់មីនផ្ទាល់របស់ខ្លួន និងបានធានាដល់ការបំផ្លាញគ្រាប់មីនប្រភេទ ADAM ដែលនៅសេសសល់តិចតួចដោយការចុះកិច្ចសន្យា និងចាត់ចែងការដឹកជញ្ជូន ដើម្បីបំផ្លាញគ្រាប់មីនទាំងនេះនៅប្រទេសទីបី ។

ទោះជាក្នុងពេលនោះក្តី ខ្ញុំត្រូវតែទទួលស្គាល់ថាជាការគួរឱ្យស្លុតនិងខកចិត្ត ដោយបានឮមតិមួយចំនួនដែលបានលើកឡើង ដោយគណៈប្រតិភូចូលរួមក្នុងកិច្ចប្រជុំដែលបាននិយាយដល់ការនៅតែមិនអនុលោមតាម។

ច្បាស់ណាស់ សម្រាប់យើង ពាក្យពេចន៍នៅក្នុងមាត្រា ៤ ចែងច្បាស់ណាស់ នៅពេលដែលមាត្រានេះចែងអំពីការបំផ្លាញនិង<u>ការធានាចំពោះការបំផ្លាញ</u>។ យើងបានបំផ្លាញមីនជិត ៣ លានគ្រាប់ និង បានធានាឱ្យមានការបំផ្លាញគ្រាប់មីនជាង ២២.០០០គ្រាប់បន្ថែមទៀត។

លោកប្រធានជាទីគោរព

ស្មារតីនៃមាត្រា ៤ របស់ប្រទេសទួរគី ត្រូវបានអនុវត្តពេញលេញ ដោយប្រើតែធនធានជាតិតែប៉ុណ្ណោះ។ សូមអនុញ្ញាតិឱ្យខ្ញុំរំលឹកសហសេវិកថាកន្លែងបំផ្លាញយុទ្ធភ័ណ្ឌទំនើបដែលគ្រាប់មីនជិត ៣ លានគ្រាប់ត្រូវបានបំផ្លាញ ត្រូវបានសាងសង់ដាច់តែឯង ដើម្បីអនុវត្តដំណើរការបំផ្លាញ ដែលមាត្រា ៤ នៃអនុញ្ញានេះបានកំណត់។

លោកប្រធានជាទីគោរព

ខ្ញុំសូមសង្ខេបពាក្យពេចន៍របស់ខ្ញុំដោយបញ្ជាក់ថាជំពូកនៃមាត្រា ៤ សម្រាប់ប្រទេសទួរគី ឥឡូវនេះត្រូវបានបិទជាស្ថាពរហើយ។

សូមអរគុណលោកប្រធាន